ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៥០៣/១៥-០៧-២០១០

សាលដីកា

លេខ:៥៣ក្រIII(ច)/០១-០៩-២០១១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បាន បើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី២៥-០៨-២០១១

ដែលមាន សមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សា**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៥០៣ ចុះថ្ងៃទី១៥-០៧-២០១០ រវាង:

១-ឈ្មោះ [redacted] ហ្វូ ហៅ ហ្វុត ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ កើតនៅទីរួមខេត្តព្រៃវែង មុខរបរជាងជួសជុលរថយន្ត ទីលំនៅមុនពេលឃាត់ខ្លួនសណ្ឋាគារ [redacted] បន្ទប់ [redacted] សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន ។

**ជាប់ចោទពីបទ:** ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅបន្ទប់លេខ២០២ សណ្ឋាគារស៊ីធីវីឡា រាជធានីភ្នំពេញ កាលពីថ្ងៃទី២២.០៧.២០០៩ ផលិតគ្រឿងញៀនខុសច្បាប់ និងបទ កាន់កាប់អាវុធខុសច្បាប់ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី, ៣២.១ថ្មី និងមាត្រា ២០ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

មានមេធាវីលោក [redacted] ចន្ថា



Scanned with CamScanner

២-ឈ្មោះ [redacted] អៀវមាន ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើតក្រោយវាំង ក្រុងភ្នំពេញ មុខរបរត់ម៉ូតូឌុប ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល [redacted] សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ជីវ៉ាន់ ទោសពីមុនគ្មាន ។

មានមេធាវីលោក [redacted] ចន្ថា

៣-ឈ្មោះ [redacted] ធី ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរធ្វើក្រចក ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល [redacted] សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] ថាំងនី (ស) ម្តាយឈ្មោះ [redacted] ថន (រ) ប្តីឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។

ជាប់ចោទពីបទៈជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅសណ្ឋាគារស៊ីធីវីឡា សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២២.០៧.២០០៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានមេធាវីលោកស្រី [redacted] មានចំប៉ា

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-០៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ធី , [redacted] ហួ និង [redacted] អៀវមាន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រទណ្ឌលេខៈ០៣(ក្រ៦)"ជ" ចុះថ្ងៃទី២៦-០៣-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃ សាលក្រមទាំងមូល ។

ឯរឿងហេតុមានដូចតទៅៈ

កាលពីថ្ងៃទី២២-០៧-២០០៩ ឈ្មោះ [redacted] ធី ភេទស្រី និងឈ្មោះ [redacted] ហួ ហៅ ហួក និងគូកនបានទំនាក់ទំនងគ្នាលក់គ្រឿងញៀន ហើយក៏ត្រូវបានសមត្ថកិច្ចនៃមន្ទីរប្រឆាំងគ្រឿងញៀនធ្វើការបង្ក្រាប និងឃាត់ខ្លួនឈ្មោះ [redacted] ធី នៅចំណុចរង្វង់មូលនាងកង្ហីងសង្កាត់អូរឬស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ ហើយក៏បានធ្វើការបន្តឃាត់ខ្លួនឈ្មោះ [redacted] ហួ ហៅ ហួក និងឈ្មោះ [redacted] អៀវមាន នៅថ្ងៃទី២៣.០៧.២០០៩ ព្រមទាំងដកហូតវត្ថុតាងគ្រឿងញៀនម្សៅប្រភេទខេតាមីនចំនួន០១កូនថង់ និងគ្រឿងញៀនគ្រាប់អ៊ិចស្តាស៊ីចំនួន៥០គ្រាប់ ។ សមត្ថកិច្ចបានបន្តឆែកឆេរនៅបន្ទប់លេខ២០២ សណ្ឋាគារស៊ីធីវីឡា និងដកហូតវត្ថុតាំងពីទូដែកមានគ្រឿងញៀនគ្រាប់ប្រភេទ អ៊ិចស្តាស៊ីចំនួន១៤៣០គ្រាប់ ទម្ងន់៤១១.៨៤ក្រាម ,គ្រឿងញៀនគ្រាប់ប្រភេទយ៉ាម៉ាសញ្ញា( WY ) ចំនួន៩៦៦ គ្រាប់ ទម្ងន់១០២.៨០ ក្រាម គ្រឿងញៀនម្សៅប្រភេទខេតាមីនចំនួន១១កូនថង់ ទម្ងន់៣៣ក្រាម គ្រឿងញៀនម្សៅពណ៌ប្រផេះ ប្រភេទហេរ៉ូអ៊ីនចំនួន១ដុំតូចទម្ងន់៥២.៧៥ ក្រាម គ្រឿងញៀនម្សៅពណ៌ក្រម៉ៅចំនួន០១ថង់ ទម្ងន់២៧០.៨០ ក្រាម ពុំសំរាប់កែច្នៃគ្រឿងញៀន មួយកំប្លេ និងអាវុធខ្លីចំនួន០១ដើម ធុន QSZ92 លេខ០០០៧០៦៦ ។ រីឯមេក្លោងឈ្មោះ ជីញ ជនជាតិចិនតៃវ៉ាន់ រត់គេចខ្លួនបាត់ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខៈ០៣(ក្រ៦) ជ ចុះថ្ងៃទី២៦-០៣-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសឈ្មោះ [redacted] ហ្វូ ហៅ ហ៊ុក ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់៩ឆ្នាំ (ប្រាំបួនឆ្នាំ) លើបទជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅបន្ទប់លេខ ២០២ សណ្ឋាគារស៊ីធីវីឡា សង្កាត់បេងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២២.០៧.២០០៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ,លើបទផលិតគ្រឿងញៀនកំណត់ ៤ឆ្នាំ (បួនឆ្នាំ) ប្រព្រឹត្តនៅរាជធានីភ្នំពេញ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០០៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ សរុបទោសត្រូវជាប់ពន្ធនាគារចំនួន១៤ឆ្នាំ (ដប់បួនឆ្នាំ) គិតពីថ្ងៃឃាត់ខ្លួន ថ្ងៃទី ២៣.០៧.២០០៩ និងពិន័យជាប្រាក់សរុបចំនួន២០ ០០០ ០០០ រៀល (ម្ភៃលានរៀល) ។

២.ផ្តន្ទាទោស

ក/ឈ្មោះ [redacted] អៀវមាន ហៅ បៀង ភេទប្រុស អាយុ៣៨ឆ្នាំ

ខ/ឈ្មោះ [redacted] ធី ហៅ វ៉េ ភេទស្រី អាយុ៤០ឆ្នាំ

ដាក់ពន្ធនាគារម្នាក់ៗកំណត់៩ឆ្នាំ (ប្រាំបួនឆ្នាំ) គិតពីថ្ងៃឃាត់ខ្លួន (២៣.០៧.២០០៩) និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ១៥ ០០០ ០០០ រៀល (ដប់ប្រាំលានរៀល) ពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២០២ សណ្ឋាគារស៊ីធីវីឡា សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២២.០៧.២០០៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.វត្ថុតាងមានៈ

-ស្រោមសំបុត្រពណ៌តគីធំបិទជិតមានសរសេរឈ្មោះជនល្មើស [redacted] អៀវមាន ភេទប្រុស ជនជាតិខ្មែរ ឈ្មោះ [redacted] ហ្វូ ភេទប្រុស ជនជាតិវៀតណាម និងមានបោះត្រាមន្ទីរប្រឆាំងគ្រឿញៀន ស្នាមម្រាមដៃជនល្មើស ដែលមានបរិមាណសារធាតុញៀនសុទ្ធទម្ងន់សរុប៥៩.៣៧ ក្រាម ។

-ពុម្ពផលិតគ្រឿងញៀន(ដែក) ចំនួន០៣ ដែលមានឡុត និងបណ្តូលនៅខាងក្នុង រឹបអូសបំផ្លាញចោល ។ តាមមាត្រា៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-អាវុធខ្លីចំនួន០១ដើម ម៉ាក QSZ92 លេខ០០០៧០៦៦ រឹបអូសដាក់ជាសម្បត្តិរដ្ឋ ។

-សាលក្រមនេះជំនុំជំរះថ្ងៃទី២៣.០២.២០១០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈថ្ងៃទី២៦.០៣.២០១០ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញរបាយការណ៍ ចុះថ្ងៃទី១៥-១០-២០១០របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៧-១២-២០១០ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។



Scanned with CamScanner

នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] ហ្វូ ហៅ ហ្វុក បានឆ្លើយថាៈ ខ្លួនបដិសេធចម្លើយនៅសមត្ថកិច្ច ដោយហេតុថាខ្លួនឆ្លើយនោះ គឺប៉ូលីសបង្ខំឲ្យខ្លួនឆ្លើយ ។ ចំពោះចម្លើយនៅអយ្យការពុំមានការបង្ខិតបង្ខំទេ ប៉ុន្តែប៉ូលីសបានប្រាប់ខ្លួនថា ឲ្យខ្លួនឆ្លើយដូចនៅប៉ូលីស ។ រីឯចម្លើយនៅតុលាការពុំមានការបង្ខិតបង្ខំទេ ពិតជាចម្លើយរបស់ខ្លួនមែន ។ ថ្នាំញៀនដែលសមត្ថកិច្ចឆែកឆេរកឃើញនៅក្នុងទូរដែកក្នុងបន្ទប់២០២ ក្នុងសណ្ឋាគារស៊ីធីវីឡា នោះមិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ ជីញ ជនជាតិចិន ហើយកាំភ្លើង និងពុម្ពដែកសំរាប់ផលិតគ្រឿងញៀនក៏ជារបស់ឈ្មោះ ជីញ ដែរ ។ ឈ្មោះ [redacted] ធី ខ្លួនមិនដែលស្គាល់ទេ រីឯឈ្មោះ តាំង អៀវមាន ហៅ បៀង ខ្លួនធ្លាប់ស្គាល់នៅពេលប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ។ នៅពេលសមត្ថកិច្ចចាប់ខ្លួន គឺខ្លួននៅក្នុងខារ៉ាអូខេយីហោ៣៨២ ។ ខ្លួនសំណូមពរសុំតុលាការលើកលែងចោទប្រកាន់ ពីព្រោះខ្លួនពុំបានប្រព្រឹត្តបទរកស៊ីជួញដូរ គ្រឿងញៀនទេ ។ ចំពោះការប្រើប្រាស់ថ្នាំញៀន ខ្លួនពិតជាបានប្រើប្រាស់មែន ។

សំណូមពរសុំឲ្យជួយរកយុត្តិធម៌ឲ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] អៀវមាន ហៅ បៀង បានឆ្លើយថាៈ ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅពេលដែលខ្លួនកំពុងបើកឡាននៅម្តុំបឹងត្របែក ។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតពីខ្លួនមានចំនួនបីគ្រាប់ ជារបស់ឈ្មោះ ហ្វុក បានឲ្យខ្លួនទុកសំរាប់ប្រើប្រាស់ ។ ហើយឈ្មោះ ហ្វុក ធ្លាប់បានឲ្យខ្លួនយកកញ្ចប់គ្រឿងញៀនដែលបានឆែកក្នុងទូរ ដែកនៅក្នុងបន្ទប់លេខ២០២ គឺជារបស់ឈ្មោះ ហ្វុក មិនមែនរបស់ខ្លួនទេ ហើយខ្លួនក៏មិនដែលបានរកស៊ីគ្រឿងញៀនដូចការចោទប្រកាន់ទេ ។ ចម្លើយនៅសមត្ថកិច្ចគេឆក់ខ្សែភ្លើង ហើយវាយឲ្យផ្តិតមេដៃលើកំណត់ហេតុឆែកឆេរទូរដែកទៀតផង ។ ខ្លួនសុំឲ្យតុលាការលើកលែងចោទប្រកាន់ខ្លួនពីបទជួញដូរគ្រឿងញៀន ។ រីឯការប្រើប្រាស់គ្រឿងញៀនខ្លួនពិតជាបានប្រើប្រាស់មែន ។

សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] ធី បានឆ្លើយថាៈ កាលពីថ្ងៃទី២២.០៧.២០០៩ នៅពេលដែលខ្លួនទៅទារលុយដែលជំពាក់ ស្រាប់តែមានមនុស្សដែលខ្លួនមិនស្គាល់បានទូរស័ព្ទឲ្យខ្លួនទៅយកលុយនៅម្តុំអូរឫស្សីជិតនាងគង្ហីង គេក៏នាំខ្លួនទៅប៉ុស្តិ៍ប៉ូលីសអូរឫស្សី ហើយក៏ឃាត់ខ្លួនតែម្តង ។ ពេលទៅដល់ប៉ុស្តិ៍ប៉ូលីសបានប្រាប់ខ្លួនថា ឲ្យឆ្លើយដាក់ឈ្មោះ ហ្វុក និងឈ្មោះ បៀង ជាអ្នករកស៊ីគ្រឿងញៀន ហើយប៉ូលីសនឹងដាក់ខ្លួនជាអ្នកចែកចាយគ្រឿងញៀនវិញ ។ ខ្លួនមិនដែលរកស៊ីគ្រឿងញៀនដូចការចោទប្រកាន់ទេ ខ្លួនបដិសេធចម្លើយនៅប៉ូលីស ដោយពុំចេះអក្សរ ហើយប៉ូលីសសរសេរដោយខ្លួនឯង បង្ខំឲ្យខ្លួនផ្តិតមេដៃ ។

សំណូមពរសុំឲ្យតុលាការជួយលើកលែងទោសឲ្យខ្លួនផង ។

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំងបីនាក់ ហើយម្យ៉ាងទៀតជនជាប់ចោទបានបដិសេធ គឺគ្រាន់តែជាការៈ



Scanned with CamScanner

ដោះសារតែប៉ុណ្ណោះ សុំឲ្យក្រុមប្រឹក្សាពិចារណាតាមច្បាប់ ។ សុំតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-មេធាវី [redacted] ចន្ថា ការពារជនជាប់ចោទឈ្មោះ [redacted] ហ្វូ ហៅ ហ្វុក និងឈ្មោះ [redacted] អៀវមាន សន្និដ្ឋានថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ហ្វូ ហៅ ហ្វុក និងឈ្មោះ [redacted] អៀវមាន ហៅ បៀង មិនមែនជាអ្នកជួញដូរគ្រឿងញៀន និងប្រើប្រាស់អាវុធទេ គ្រាន់តែប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ ហើយឈ្មោះ [redacted] ហ្វូ ពិតជាបានចែកឲ្យឈ្មោះ បៀង ប្រើប្រាស់មែន ។ សុំក្រុមប្រឹក្សាកែបទចោទ ជួញដូរគ្រឿងញៀន និងប្រើប្រាស់អាវុធ មកជាបទប្រើប្រាស់គ្រឿងញៀនវិញ និងសំណូមពរសុំឲ្យដោះលែងកូនក្តីខ្លួនឲ្យរួចខ្លួន ។

-មេធាវី [redacted] វិមានចំប៉ា ការពារជនជាប់ចោទឈ្មោះ [redacted] អៀវមាន សន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានសារភាពគ្រប់ដំណាក់ការទាំងអស់ពុំមានការភូតភរទេ ។ យោងតាមមាត្រា៩៣ និង ៩៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា សំណូមពរសុំលោកប្រធានក្រុមប្រឹក្សាពិនិត្យ និងពិចារណាលើ -កូនក្តីរបស់ខ្លួនមានកូនតូចៗត្រូវបីបាច់ថែរក្សា

-មានជីវភាពក្រីក្រលំបាក ពុំធ្លាប់មានទោសពីមុន

សូមក្រុមប្រឹក្សាបន្ធូរបន្ថយទោសក្រោមកម្រិតអប្បបរមានៃទោស ដល់កូនក្តីខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រូវហើយ

## សាលាឧទ្ធរណ៍

១-យល់ឃើញថា បណ្តឹងឧទ្ធរណ៍លេខ:២១៤, ២១៥ ចុះថ្ងៃទី២៩-០៣-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] អៀវមាន ហៅ បៀង ,ឈ្មោះ [redacted] ហ្វូ ហៅ ហ្វុក និងបណ្តឹងឧទ្ធរណ៍លេខ:២៣៤ ចុះថ្ងៃទី០៨-០៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ធី ប្តឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ:០៣ក្រ៦ (ជ) ចុះថ្ងៃទី២៦.០៣.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបានយោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ទោះបីជនជាប់ចោទទាំងបី បានឆ្លើយបដិសេធនាពេលសវនាការសាលាឧទ្ធរណ៍ មិនទទួលស្គាល់ការចោទប្រកាន់ថាខ្លួនប្រព្រឹត្តដូចការចោទក៏ដោយ ក៏ជនជាប់ចោទគ្មានសំអាងហេតុមកដោះសារ សម្រាប់ដោះបន្ទុកនូវអំពើ និងសកម្មភាពរបស់ខ្លួនឡើយ ។

៣-យល់ឃើញថា តាមកំណត់ហេតុឆែកឆេរចុះថ្ងៃទី២៨.០៧.២០០៩ និងការបើកទូរដែករបស់គណៈកម្មការខាងមន្ទីរប្រឆាំងគ្រឿងញៀនចុះថ្ងៃទី២៨.០៧.២០០៩ ដែលមាននៅក្នុងកំណត់ ហេតុទទួលវត្ថុតាងនៅអយ្យការលេខ:២៨៤ ចុះថ្ងៃទី២៧.០៧.២០០៩:

របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងលទ្ធផលកោសវិច័យគ្រឿងញៀនលេខ ៦១០/០៩ មពលដ ប.ក ចុះថ្ងៃទី ១៦-០៩-២០០៩ បានបញ្ជាក់ច្បាស់ថា ជារបស់ជនជាប់ចោទ ហើយលទ្ធផលមាន កេតាមីន,ហេរ៉ូអ៊ីន និងមេតំហ្វេតាមីន សារធាតុទាំងនេះគ្មានផលប្រយោជន៍វេជ្ជសាស្ត្រទេ គឺជាថ្នាំឱ្យមាន គ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់អ្នកប្រើប្រាស់ទាំងនេះ គឺជាភស្តុតាងល្មើសច្បាប់ របស់ជនជាប់ចោទសមត្ថកិច្ចចុះបង្ក្រាបបាន ។

៤-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ០៣ក្រ៦ "ជ" ចុះថ្ងៃទី ២៦-០៣-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីមានសំអាងហេតុត្រឹមត្រូវ តាមអង្គហេតុនិងអង្គច្បាប់ ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ២១៤,២១៥ ចុះថ្ងៃទី ២៩-០៣-២០១០ របស់ជនជាប់ចោទឈ្មោះ តាំង អៀវមាន ហៅ បៀង ,ឈ្មោះ ហេង ហូ ហៅ ហ៊ុក និងបណ្តឹងឧទ្ធរណ៍លេខ ២៣៤ ចុះថ្ងៃទី ០៨-០៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយ ទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៣ក្រ៦ "ជ" ចុះថ្ងៃទី ២៦-០៣-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ហូ ហៅ ហ៊ុក, [redacted] អៀវមាន ហៅ បៀង, [redacted] ធី តាមច្បាប់ ។

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី ២៤-០៨-២០១១ និងប្រកាសជាសាធារណៈថ្ងៃ ទី ០១-០៩-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហូ ហៅ ហ៊ុក , [redacted] អៀវមាន ហៅ បៀង [redacted] ធី មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះ មានអនុភាពអនុវត្តតែទៅលើឈ្មោះ [redacted] អៀវមាន (ហៅ បៀង) ម្នាក់ប៉ុណ្ណោះ ក្រៅពីនេះមិនទាន់មានអនុភាពអនុវត្តនៅឡើយទេ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី ៤ ខែ ៧ ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner